UNITED NATIONS
CAMBODIA

# សេចក្តីប្រកាសព័ត៌មាន

## សម្តេចនាយករដ្ឋមន្ត្រី និងតំណាងអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ជួបពិភាក្សាអំពីវឌ្ឍនភាព និងភាពលំនុងវត្តន៍ភាពសម្រាប់ការអភិវឌ្ឍប្រកបចីរភាព

**ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៩** – ព្រឹកនេះ **លោកស្រី** Pauline Tamesis អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា បានដឹកនាំគណៈប្រតិភូមួយនៃសមាជិកក្រុមការងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ដើម្បីជួបប្រជុំជាមួយនឹង**សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងកិច្ចពិគ្រោះយោបល់ដែលរៀបចំជារៀងរាល់ឆ្នាំ។

កិច្ចប្រជុំពិគ្រោះយោបល់នេះ មានគោលបំណងពិភាក្សាពីបញ្ហាសំខាន់ៗ ជុំវិញការអភិវឌ្ឍប្រកបដោយចីរភាព ដែលត្រូវបានរំលេចក្នុងក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDAF) រយៈពេល ៥ ឆ្នាំ ដើម្បីពន្លឿនការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។

លោកស្រី Tamesis មានប្រសាសន៍ក្នុងសុន្ទរកថារបស់លោកស្រីថា "ក្នុងរយៈពេល ៥ ឆ្នាំទៀត អង្គការសហប្រជាជាតិ នឹងផ្តល់ការគាំទ្រជាយុទ្ធសាស្ត្រដល់អាទិភាពនៃការអភិវឌ្ឍជាតិ ដូចដែលត្រូវបានដាក់ចេញក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី IV, សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា"។

នៅឆ្នាំនេះ កិច្ចប្រជុំពិគ្រោះយោបល់នេះ ផ្តោតលើប្រធានបទសំខាន់ៗចំនួន ៣ គឺ *កិច្ចគាំពារសង្គម ទិន្នន័យសម្រាប់ការអភិវឌ្ឍ និងវឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព៖*

- **កម្មវិធីគាំពារសង្គម** ដែលមានប្រសិទ្ធភាព អាចជួយសម្រួលសម្រាលបន្ទុកហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋក្រីក្រ, ជួយគ្រួសារងាយរងគ្រោះឱ្យទទួលបានសេវាសង្គម និងលើកកម្ពស់សុខុមាលភាពជារួមរបស់ពួកគេ, ព្រមទាំងកាត់បន្ថយភាពងាយរងគ្រោះ និងការពារប្រជាពលរដ្ឋពីហានិភ័យនានា។ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់នេះ ភាគីទាំង ២ បានពិភាក្សាពីសារៈសំខាន់នៃការពង្រឹងក្របខ័ណ្ឌស្ថាប័ន ការសម្របសម្រួលពហុវិស័យ កិច្ចខិតខំប្រឹងប្រែង

UNITED NATIONS CAMBODIA

រួមគ្នា ដើម្បីគាំទ្រដល់ក្រុមដែលងាយរងគ្រោះជាងគេ ដើម្បីឱ្យពួកគេអាចទទួលបានប្រយោជន៍ពីកម្មវិធីគាំពារសង្គមនានា ព្រមទាំងការវិនិយោគថវិកា ដែលចាំបាច់ ដើម្បីគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៦-២០២៥)។

- **<u>ទិន្នន័យសម្រាប់ការអភិវឌ្ឍ</u>** ដែលមានគុណភាព អាចជួយឱ្យអាជ្ញាធរជាតិទទួលបាន និងប្រើប្រាស់ទិន្នន័យបែងចែកតាមប្រភេទ ទាន់ពេលវេលា និងអាចជឿទុកចិត្តបាន។ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា កំពុងសហការគ្នា ដើម្បីធានាយ៉ាងណាឱ្យគោលការណ៍ "មិនទុកនរណាម្នាក់ចោល" ត្រូវបានបញ្ចូល ទៅក្នុងផែនការអភិវឌ្ឍន៍ជាតិនានា សំដៅឱ្យផែនការទាំងនេះ ប្រកបដោយសង្គតិភាព មានលក្ខណៈបរិយាប័ន្ន និងសមធម៌។ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានពិភាក្សាអំពីកាលានុវត្តភាព និងការវិនិយោគចាំបាច់នានា ដើម្បីពង្រឹងប្រព័ន្ធស្ថិតិជាតិ សម្រាប់តាមដានគោលដៅរបស់ជាតិ និងចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។
- រាជរដ្ឋាភិបាលកម្ពុជា កំពុងត្រៀមរៀបចំ ដើម្បីធ្វើបទបង្ហាញ**<u>ការត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត (VNR)</u>** ដែលផ្តោតលើផែនការអនុវត្តន៍ និងវឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា ក្នុងសម័យប្រជុំនៃវេទិកានយោបាយកម្រិតខ្ពស់ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព នៅទីក្រុងញូវយ៉ក ក្នុងខែ កក្កដា ខាងមុខនេះ។ ការត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តនេះ គឺជាកាលានុវត្តន៍ភាពដ៏សំខាន់មួយ ដើម្បីឱ្យកម្ពុជាអាចបង្ហាញពីសមិទ្ធផល និងបទពិសោធន៍ជោគជ័យនៃការអភិវឌ្ឍរបស់ខ្លួនទៅកាន់ពិភពលោកទាំងមូល ទាំងទៅកាន់ប្រទេសជាមិត្តផង និងអ្នកផ្តល់ជំនួយផង។

លោកស្រី Pauline Tamesis បានបន្ថែមទៀតថា "ដើម្បីបោះជំហានទៅមុខ ទាមទារអោយមានការយកចិត្តទុកដាក់ខ្ពស់ជាអទិភាពរវាងតុល្យភាពនៃកំនើនសេដ្ឋកិច្ច ជាមួយនឹង ការការពារ បរិស្ថានធម្មជាតិ ការការពារសិទ្ធិមនុស្ស និងការលើកកម្ពស់គោលដៅសង្គម ដើម្បីធានាថាប្រជាជនក្រីក្រត្រូវបានការពារពីហានិភ័យ និងធានាថាវិបុលភាពត្រូវបានចែករំលែកប្រកបដោយសមធម៌ ហើយជំនាន់ក្រោយៗទៀតក៏ទទួលបានអត្ថប្រយោជន៍ពីការសម្រេចចិត្តថ្ងៃនេះ អំពីរបៀបដែលធនធានត្រូវបានគ្រប់គ្រង។"

UNITED NATIONS
CAMBODIA

បន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់លើប្រធានបទខាងលើនេះ មានការចុះហត្ថលេខាលើក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDAF) ២០១៩ ដល់ ២០២៣ ដោយលោកស្រី Pauline Tamesis អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា និង**ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

UNDAF ថ្មីនេះ ផ្តោតលើអាទិភាពនៃការអភិវឌ្ឍនចំនួន ៥៖ ១) ពង្រីកឱកាសសង្គម, ២) ពង្រីកឱកាសសេដ្ឋកិច្ច, ៣) លើកកម្ពស់ការរស់នៅប្រកបដោយចីរភាព, ៤) ពង្រឹងការចូលរួម និងគណនេយ្យភាព, និង ៥) គ្រប់គ្រងនគរូបនីយកម្ម។

លោកស្រី Tamesis មានប្រសាសន៍ថា "ក្នុងក្របខ័ណ្ឌUNDAF ថ្មីនេះ អង្គការសហប្រជាជាតិនឹងផ្តល់ការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេសដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំ និងអនុវត្តផែនការគោលនយោបាយ និងក្របខ័ណ្ឌនានា ដើម្បីចាត់អាទិភាពលើបញ្ហានានា ដែលមានផលប៉ះពាល់លើក្រុមដែលងាយរងគ្រោះជាងគេ"។

* * *

*សម្រាប់សំណួររបស់អ្នកសារៈព័ត៌មាន សូមទាក់ទង៖*

***លោកស្រី សារុំ មនោរី*** *មន្ត្រីទំនាក់ទំនងនៃការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ទូរសព្ទ៖ +855 12 690 495, អ៊ីមែល៖ monory.sarom@one.un.org*

*លោក Tim Jenkins ទីប្រឹក្សាផ្នែកទំនាក់ទំនងនៃការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ទូរសព្ទ៖: +855 (0) 76 209 2612, អ៊ីមែល៖ timothy.jenkins@one.un.org*

*អំពីអង្គការសហប្រជាជាតិនៅកម្ពុជា៖ អង្គការសហប្រជាជាតិនៅកម្ពុជា ដើម្បីគាំទ្រដល់សន្តិភាព ការលុបបំបាត់ភាពក្រីក្រ និងលើកកម្ពស់សិទ្ធិមនុស្សក្នុងប្រទេសនេះ។ អង្គការសហប្រជាជាតិប្តេជ្ញាបង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍ ដើម្បីគាំទ្រដល់អាទិភាព ផែនការ និងកម្មវិធីនានា របស់រាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល និងដៃគូពាក់ព័ន្ធដទៃទៀត។*